00612987

F5/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 10 / 2010
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខៈ ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម Agnieszka KLONOWIECKAMILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew T. CAYLEY

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រ៊ីនណា

Karim KHAN
Alain WERNER
Brianne McGONIGLE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU



E.C.C.C * C.E.T.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

00612989



F5/2

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក") បានទទួល"សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន" ("សំណើសុំទីមួយ")[1] និង"សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន" ("សំណើសុំទីពីរ")[2]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់"សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច"("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ")[3]។ នៅថ្ងៃទី០៧ និងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់សំណើសុំទីមួយ និងសំណើសុំទីពីរ("សំណើសុំ") អនុលោមតាមមាត្រា៥(៤)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")[4]។

២. នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច បានជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូលថា ខ្លួននឹងមិនដាក់ចម្លើយតបទៅនឹងសំណើសុំទីពីរនេះទេ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចនេះ មុនកាលផុតកំណត់នៃរយៈពេលដែលសហមេធាវីការពារក្តី អាចដាក់ចម្លើយតបបាន[5] ។

## II. ផ្នែកសំអាងហេតុ

### ក. ច្បាប់ជាធរមាន

៣. ផ្នែកដែលពាក់ព័ន្ធនៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មានដូចខាងក្រោម៖

> ឯកសារដែលដាក់នៅ ... អង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក មិនត្រូវឲ្យលើសពី៣០ ទំព័រជាភាសាអង់គ្លេស ឬ បារាំង ឬ ៦០ទំព័រជាភាសាខ្មែរ លើកលែងតែមានបទប្បញ្ញត្តិចែង

---

[1] ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ F5/1។

[2] ថ្ងៃទី២៩ ខែកញ្ញា ២០១០, F5/1។

[3] E188/2។

[4] អ.វ.ត.ក/០១/២០០៧/វ.០៤("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")

[5] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨(៣)។

ផ្ទុយពីនេះ នៅក្នុងវិធានផ្ទៃក្នុងនៃអ.វ.ត.ក ឬ សេចក្ដីណែនាំអនុវត្ត ឬ បទបញ្ជាចេញដោយ អ.វ.ត.ក។

....

តាមការស្នើសុំរបស់ភាគីចូលរួម សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធអាច បង្កើនចំនួនទំព័រនៃឯកសារទៅតាមកាលៈទេសៈពិសេស[6]។

## ខ. ការទទួលយកទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់

៤. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំណើសុំត្រូវបានដាក់មុនកាលបរិច្ឆេទក្នុងការដាក់សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[7]។ សំណើនេះ បានពន្យល់អំពីកាលៈទេសៈពិសេសដែលយោងតាមសហព្រះរាជអាជ្ញាតម្រូវឱ្យមានការដាក់ឯកសារដែលមានចំនួនទំព័រលើសការកំណត់។ ហេតុដូច្នេះ សំណើសុំនេះ អាចទទួលយកទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

## គ. អង្គសេចក្ដី

៥. សំណើសុំទី១ បានស្នើសុំបន្ថែមចំនួន១៥ទំព័រទៀត សម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជាភាសាអង់គ្លេសដោយលើកហេតុផលដូចខាងក្រោម៖

> ភាគច្រើននៃបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបណ្ដឹងសាទុក្ខបន្ទាន់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ជាតួយ៉ាង ពាក់ព័ន្ធនឹងបញ្ហាតែមួយ ឬ បញ្ហាមួយចំនួនមានកម្រិតដែលអាស្រ័យតាមប្រភេទនៃសេចក្ដីសម្រេចដែលកំពុងតវ៉ា។ ប៉ុន្តែ អាស្រ័យទៅតាមប្រភេទរបស់វា បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម គឺពាក់ព័ន្ធទៅនឹងការភាន់ច្រឡំមួយចំនួននៃអង្គហេតុ និងអង្គច្បាប់នៃសាលក្រមធម្មតាដ៏វែងមួយ ដែលបញ្ហានេះ ត្រូវបានលើកឡើងក្នុងអំឡុងពេលជំនុំជម្រះក្ដីទាំងមូល[8]។ ដូចបណ្ដឹងសាទុក្ខមួយនេះជាដើម ចំពោះបណ្ដឹង

---

[6] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ, មាត្រា៥(២), ៥(៤)។

[7] សំណើសុំ, កថាខ័ណ្ឌ ១២។

[8] លេខយោងទី០៨ នៅក្នុងសំណើសុំបញ្ជាក់ថា "សាលក្រម បានរួមបញ្ចូលការវិភាគនៃអង្គច្បាប់និងអង្គហេតុ និងសេចក្ដី... លើទំព័រ២៤៦ បន្ថែមទៅលើប្រវត្តិនីតិវិធីចំនួន១០ទំព័រ"។



E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

សាទុក្ខដែលជំទាស់នឹងសាលក្រម គឺមានលក្ខណៈខុសប្លែកពីបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ និង សក្តិសមទទួលបាននូវការអនុញ្ញាតបន្ថែមចំនួនទំព័រច្រើនជាងនេះ។

...

សហព្រះរាជអាជ្ញារំពឹងទុកថា ទឡ្ហីករណ៍ទី[នៃបណ្តឹងសាទុក្ខដែលបានរៀបរាប់ក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ] និងជាពិសេសទឡ្ហីករណ៍បន្ទាប់បន្សំ តម្រូវឲ្យធ្វើការវិភាគយ៉ាងល្អិតល្អន់លើសំអាងហេតុ និងសំអាងផ្លូវច្បាប់[អង្គជំនុំជម្រះសាលាដំបូង]ក្នុងសាលក្រម និងក្នុងដីកាសន្និដ្ឋាននានាដូចមានចែងនៅក្នុងសេចក្តីសន្និដ្ឋានបិទសវនាការរបស់សហព្រះរាជអាជ្ញា ដែលបង្ហាញសក្ខីកម្មឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូង (ក) បានផ្តល់ស្ថានទម្ងន់ទោសមិនគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មរបស់ឌុចលើតួនាទី និងចេតនាក្នុងការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ និងស្ថានទម្ងន់ទោសផ្សេងៗទៀត។ (ខ) បានផ្តល់ស្ថានសម្រាលទោសជ្រុលហួសហេតុ។ និង (គ)ដាក់ទោសក្រៅវង្វង់នៃការផ្តន្ទាទោសដែលអាចធ្វើទៅបានក្នុងកាលៈទេសៈបែបនេះ។ ស្រដៀងគ្នានេះដែរ ទឡ្ហីករណ៍ទី II និងទី III ក៏តម្រូវឲ្យមានការពិនិត្យពិច័យយ៉ាងល្អិតល្អន់ទៅលើយុត្តិសាស្ត្រដែលអាចអនុវត្តបានផងដែរ។

ការរៀបចំសរសេរជាលំអិតអំពីទឡ្ហីការណ៍ទាំងបីនេះ គឺត្រូវការចំនួនទំព័រប្រហែលជាសែសិបទំព័រ។ សហព្រះរាជអាជ្ញា នឹងចាំបាច់ត្រូវបន្ថែមចំនួនទំព័រប្រាំទំព័រទៀត សម្រាប់ធ្វើសេចក្តីសន្និដ្ឋានបឋម និងសេចក្តីសន្និដ្ឋានផ្នែកនីតិវិធី ដែលក្នុងនោះរួមទាំងប្រវត្តិនៃនីតិវិធី និងសេចក្តីសន្និដ្ឋាន ទំនងជានិយាយអំពីបញ្ហាការធ្វើសវនាការជាសាធារណៈនៃបណ្តឹងសាទុក្ខ[9]។

៦. សំណើទីពីរ ស្នើសុំបន្ថែមចំនួនម្ភៃទំព័រទៀតដោយលើកហេតុផលដូចខាងក្រោម៖

ឥឡូវនេះ សហព្រះរាជអាជ្ញា បានបំពេញរួចរាល់ហើយនូវសារណាលើបណ្តឹងសាទុក្ខដោយពិនិត្យមើលម៉ត់ចត់លើការរកឃើញនានាផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងសាលក្រម ដើម្បីគាំទ្រដល់បណ្តឹងសាទុក្ខរបស់ខ្លួន ។ ក៏ប៉ុន្តែ សេចក្តីព្រាងចុងក្រោយជាភាសាអង់គ្លេស រួមទាំងទំព័រមុខមាតិការឿង និងសេចក្តីសន្និដ្ឋានទាក់ទងនឹងនីតិវិធី និងសេចក្តីសន្និដ្ឋានដ៏មានសារៈសំខាន់ផង បានកើនឡើងរហូតទៅដល់៦៥ទំព័រ។ បន្ទាប់ពីការវាយតម្លៃជាលម្អិតមួយទៅលើសេចក្តីសន្និដ្ឋានលើបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា ការកាត់បន្ថយណាមួយចេញពីចំនួនទំព័រខាងលើនេះ គឺមុខជានឹងធ្វើឲ្យខូចដល់បូរណភាពនៃសេចក្តីសំអាងរបស់ខ្លួន ហើយនឹងមិនបំម្រើឲ្យផលប្រយោជន៍នៃយុត្តិធម៌នោះឡើយ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើដល់

---

[9] សំណើសុំ កថាខណ្ឌ២,៦-៧(លេខយោងបានលុបចោល)។ មើលសំណើសុំ កថាខ័ណ្ឌ៣-៤។



E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

F5/2

អង្គជំនុំជម្រះតុលាការកំពូល បន្ថែមចំនួនទំព័រពីលើចំនួនកំណត់រហូតដល់អតិបរមា៦៥ទំព័រជាភាសាអង់គ្លេស។ មូលហេតុនៃការបន្ថែមចំនួនទំព័រខាងលើនេះ ជាសំខាន់គឺវាដូចគ្នានឹងមូលហេតុដែលបានលើកឡើងនៅក្នុងពាក្យសុំលើកទីមួយដែរ ហើយហេតុនេះ ត្រូវបានរួមបញ្ចូលនៅក្នុងនេះដោយការលើកជាសេចក្តីយោង *ដោយមានការកែប្រែប្រសិនបើមានការចាំបាច់*[10]។

៧. អង្គជំនុំជម្រះតុលាការកំពូលឯកភាពជាមួយនឹងសហព្រះរាជអាជ្ញាថា "តុលាការព្រហ្មទណ្ឌអន្តរជាតិដែលធ្វើការកាត់សេចក្តីចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ និងទំហំស្រដៀងគ្នានឹងអ.វ.ត.ក ក៏បានអនុញ្ញាតផ្តល់ចំនួនទំព័រ (ឬ ចំនួនពាក្យពេចន៍)ច្រើនជាង សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមផងដែរ"[11]។ នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាឧទាហរណ៍ "ឯកសារគាំទ្រដល់បណ្តឹងសាទុក្ខ មិនត្រូវលើសពីចំនួន១០០ទំព័រឡើយ"[12]។

៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សហព្រះរាជអាជ្ញាបានបង្ហាញអំពីកាលៈទេសៈពិសេសកើតមាននៅក្នុងករណីនេះ ដែលចាំបាច់បន្ថែមចំនួនទំព័រជាអតិបរមាចំនួន៣៥ទំព័របន្ថែមទៀតលើសារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ទទួលយកសំណើសុំនេះ។ សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជាភាសាអង់គ្លេស មិនត្រូវឲ្យលើសពី៦៥ទំព័រឡើយ។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្ថែមចំនួនទំព័រនៃបណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាខ្មែរដែលចាំបាច់ឲ្យឆ្លើយតបទៅនឹងចំនួនទំព័រនៃបណ្តឹងសាទុក្ខជាភាសាអង់គ្លេសផងដែរ។

---

[10] សំណើសុំទីពីរ កថាខណ្ឌ២។

[11] សំណើសុំទីមួយ កថាខណ្ឌ៣, សំណើសុំទីពីរកថាខណ្ឌ៤។

[12] បទប្បញ្ញត្តិរបស់តុលាការ ICC-BD/០១-០២-០៧, ចុះថ្ងៃទី ២៦ ឧសភា ឆ្នាំ២០០៤ (ត្រូវបានកែប្រែ) បទប្បញ្ញត្តិទី៥៨ សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន (ឯកសារលេខ F5/2, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០)

E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

00612993

001/18-កក្កដា-2007-អ.វ.ត.ក/អ.ជ.ត.ក F5/2

## III. ផ្នែកសេចក្តីសម្រេច

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទ÷**

១. ទទួលយកសំណើសុំទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. អនុញ្ញាតតាមសំណើសុំបន្ថែមចំនួនទំព័រ និងការបន្ថែមចំនួនទំព័រជាភាសាខ្មែរដែលចាំបាច់ឲ្យឆ្លើយតបទៅនឹងចំនួនទំព័របណ្តឹងសាទុក្ខជាភាសាអង់គ្លេស។

**រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER E.C.C.C * C.E.T.C

**គង់ ស្រ៊ឹម**